**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**
លេខ ០០២ សណណ

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០៧

# សារាចរណែនាំ
# ស្តីពី
# ការគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍

ដើម្បីគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍ អោយមានសណ្តាប់ធ្នាប់របៀបរៀបរយប្រកបដោយសន្តិសុខ សុវត្ថិភាព មានសុជីវធម៌ជូនទេសចរជាតិ-អន្តរជាតិ និងក្នុងគោលបំណងធានាការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ថែរក្សាការពារវប្បធម៌ ប្រពៃណីជាតិ តាមគោលនយោបាយអភិវឌ្ឍន៍វិស័យទេសចរណ៍ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីអនុវត្តប្រកាសលេខ ០៦២ ប្រ.ក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ ក្រសួងទេសចរណ៍សូមធ្វើការណែនាំដូចខាងក្រោម :

១ : - រាល់ការធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍ អាជីវករត្រូវមានច្បាប់អនុញ្ញាតពីក្រសួងទេសចរណ៍ ។ ទំរង់បែបបទនៃការសុំធ្វើអាជីវកម្ម ត្រូវបំពេញដោយម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍ និងត្រូវគោរពអនុវត្តតាមប្រកាសរបស់ក្រសួងទេសចរណ៍ ។

- ការដាក់ទីតាំងធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍កែច្នៃបង្កើតថ្មី ត្រូវស្ថិតនៅចម្ងាយយ៉ាងតិច ២០០ ម៉ែត្រ ពីសាលារៀន វត្តអារាម មន្ទីរពេទ្យ ស្ថានទូត និងទីកន្លែងស្ថាប័នរដ្ឋបាលសំខាន់ៗ ។
- មុននឹងចាប់ផ្តើមរាល់ការសាងសង់ ឬរៀបចំទីតាំងអាជីវកម្ម អាជីវករត្រូវមកទំនាក់ទំនងជាមួយក្រសួងទេសចរណ៍ ដើម្បីពិគ្រោះសុំការណែនាំ ។
- ឯកសារផ្សេងៗទៀត ដែលក្រសួងទេសចរណ៍ត្រូវការរួមមាន :
  - កិច្ចសន្យារបស់ម្ចាស់អាជីវកម្មចំពោះក្រសួងទេសចរណ៍ ក្នុងការប្រកបអាជីវកម្ម
  - កិច្ចសន្យាជំពាក់ឯកសារ ដែលត្រូវបំពេញឡើងវិញក្នុងរយៈពេល ០៣ ខែ
  - បើសិនការធ្វើអាជីវកម្មនេះមានការពាក់ព័ន្ធទៅនឹងក្រសួង ស្ថាប័នជំនាញណាមួយ ម្ចាស់អាជីវកម្មចាំបាច់ត្រូវសុំលិខិតបញ្ជាក់ យល់ព្រមជាមុនពីក្រសួង - ស្ថាប័ននោះ
  - ត្រូវបំពេញតារាងត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម ។

២ : ក្នុងការធ្វើអាជីវកម្ម អាជីវករត្រូវគោរពអនុវត្តតាមសារាចរណែនាំ និងបទប្បញ្ញត្តិស្តីអំពីការគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍ ច្បាប់ការងារ អនាម័យម្ហូបអាហារព្រមទាំងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀតរបស់រដ្ឋដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មទេសចរណ៍ ដើម្បីជាកិច្ចធានាដល់សន្តិសុខ សុវត្ថិភាព សុខុមាលភាពជូនទេសចរ ។

៣ : រាល់ការធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍ ត្រូវធានាថាមិនធ្វើអោយប៉ះពាល់ដល់ វប្បធម៌ ប្រពៃណីជាតិ សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន និង របៀបរៀបរយសង្គម ។

៤ : ដើម្បីពង្រឹងនូវលក្ខណៈសម្បត្តិ និងគុណភាពសេវាកម្ម អាជីវករត្រូវអនុវត្តតាមបទដ្ឋាន និងស្តង់ដាដូចខាងក្រោម :

- ត្រូវមានកន្លែងសំរាប់ចតរថយន្តគ្រប់ប្រភេទរបស់ទេសចរ
- សំបុត្រចូលទស្សនាត្រូវដាក់លក់ក្នុងបញ្ជរ
- ត្រូវរៀបចំដាក់បង្ហាញប្លង់ទីតាំង រូបសំណាកសំខាន់ៗ នៅទីកន្លែងដំបូងនៃច្រកចូល
- ត្រូវលើកផ្លាកសញ្ញាចង្អុលទីកន្លែងកំសាន្តផ្សេងៗនៅតាមគ្រប់ច្រកចេញ-ចូល និងត្រូវដាក់ផ្លាកសញ្ញាចរាចរអោយបានត្រឹមត្រូវ ដើម្បីងាយស្រួលទេសចរធ្វើដំណើរកំសាន្តក្នុងរមណីយដ្ឋាន
- ត្រូវដាក់តាំងអាជ្ញាប័ណ្ណទេសចរណ៍នៅកន្លែងទទួលភ្ញៀវ
- បុគ្គលិក-កម្មករបំរើការងារក្នុងរមណីយដ្ឋានទេសចរណ៍ ត្រូវមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ និងមានប័ណ្ណពិនិត្យសុខភាពចេញដោយនាយកដ្ឋានពេទ្យការងារ ឬ មន្ទីរសុខាភិបាលខេត្ត-ក្រុង ត្រូវមានឯកសណ្ឋានសមរម្យ និងមានផ្លាកឈ្មោះសំគាល់ ព្រមទាំងមានអាកប្បកិរិយាថ្លៃថ្នូរ សុជីវធម៌ គោរពសិទ្ធិ និងផលប្រយោជន៍ទេសចរ
- ត្រូវមានបទបញ្ជាផ្ទៃក្នុង និង ការណែនាំអំពីវិធីបង្ការគ្រោះថ្នាក់ផ្សេងៗ ប្រសិនបើមានល្បែងកំសាន្តក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួន និងត្រូវមានតារាងកំណត់តំលៃនិមួយៗអោយបានច្បាស់លាស់
- ក្នុងរមណីយដ្ឋាន ត្រូវមានផ្លាកសញ្ញាសំគាល់ឈ្មោះរុក្ខជាតិធំៗ និងឈ្មោះសត្វគ្រប់ប្រភេទ ជាភាសាជាតិ និងអន្តរជាតិ ព្រមទាំងមានសញ្ញាប្រុងប្រយ័ត្ន ឬហាមឃាត់នៅតំបន់មានគ្រោះថ្នាក់ ឬតំបន់មានជ្រោះ
- ត្រូវមានកៅអីវែង ឬ បង់អង្គុយសំរាក លំអទៅដោយសួនច្បារ សួនស្មៅ ក្បូរក្បាច់រចនាម៉ូត ប្រកបដោយសោភ័ណភាព
- ត្រូវបំពាក់គ្រឿងឧបករណ៍ការពារសុវត្ថិភាព អោយបានគ្រប់គ្រាន់ និងត្រូវថែទាំពិនិត្យជាប្រចាំ ព្រមទាំងត្រូវផ្លាស់ប្តូរថ្មីជាបន្ទាន់ពេលមានការខូចខាត ឬចាស់ ទ្រុឌទ្រោម
- ត្រូវមានរថយន្តពន្លត់អគ្គីភ័យ និងឧបករណ៍ពន្លត់អគ្គីភ័យផ្សេងៗទៀត ព្រមទាំងវិទ្យុទាក់ទង សំរាប់ប្រើប្រាស់ពេលមានការចាំបាច់
- ត្រូវមានផ្នែកសង្គ្រោះបន្ទាន់ និងមានទូរថ្នាំពេទ្យសង្គ្រោះ ព្រមទាំងបុគ្គលិកប្រចាំការ ដើម្បីត្រៀមលក្ខណៈជួយដល់ភ្ញៀវទេសចរនៅពេលមានគ្រោះថ្នាក់ជាយថាហេតុ មុនពេលភ្នាក់ងារសុខាភិបាលមកដល់ ឬមុនពេលបញ្ជូនទៅមន្ទីរពេទ្យដែលនៅជិតបំផុត
- ហាមមានអាវុធ ជាតិផ្ទុះ នៅក្នុងរមណីយដ្ឋាន
- ត្រូវធ្វើអនាម័យជាប្រចាំ មានធុងសំរាមដាក់តាមតំបន់នានាក្នុងទីសាធារណៈ និងកន្លែងកំសាន្ត

- ត្រូវមានបង្គន់អនាម័យសំរាប់បុរស និងនារីដោយសំអាតជាប្រចាំ និងត្រូវរៀបចំអោយមានចំនួនបង្គន់សមស្រប ទៅនឹងចំនួនទេសចរ និងទំហំផ្ទៃដីរបស់រមណីយដ្ឋាន
- ត្រូវមានមគ្គុទ្ទេសក៍ទេសចរណ៍ ដែលមានសមត្ថភាព និង បទពិសោធន៍សំរាប់ជូនដំណើរទេសចរកំសាន្តនៅក្នុង រមណីយដ្ឋានទាំងមូល ។

៥ : ការដាក់លក់ម្ហូបអាហារ ត្រូវបានអនុញ្ញាតលើទីតាំងសមស្រប ប៉ុន្តែត្រូវមានកិច្ចសន្យាច្បាស់លាស់ ។

៦ : ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ត្រូវសហការ និងរាយការណ៍ជាបន្ទាន់ ជូនអាជ្ញាធរមានសមត្ថកិច្ច និងមន្ទីរ ទេសចរណ៍ នូវរាល់បាតុភាពមិនប្រក្រតីដែលអាចកើតឡើង ឬបានកើតឡើងនៅទីកន្លែងអាជីវកម្ម ។

៧ : ក្នុងករណីមិនគោរពតាមបទប្បញ្ញត្តិ ស្តីពីការធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍ អាជីវករត្រូវទទួលការផាក ពិន័យតាមច្បាប់កំណត់ ។ ករណីធ្វើអោយមានការប៉ះពាល់ធ្ងន់ធ្ងរ ដល់សុវត្ថិភាព ឬបង្កអោយមានគ្រោះថ្នាក់ដល់ ទេសចរត្រូវទទួលទោសតាមច្បាប់រដ្ឋ ។

៨ : ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីប្រកបអាជីវកម្ម រមណីយដ្ឋានទេសចរណ៍ តាមរយៈមន្ទីរទេសចរណ៍ខេត្ត-ក្រុង ដែលត្រូវត្រួតពិនិត្យ និងអនុញ្ញាតដោយក្រសួង ទេសចរណ៍ ។

៩: ក្នុងករណីចាំបាច់ក្រសួងនឹងមានវិធានការចាត់តាំងអធិការ និងមន្ត្រីជំនាញ ចុះធ្វើអធិការកិច្ចលើការអនុវត្តន៍លិខិត បទដ្ឋានស្តីពីអាជីវកម្មរមណីយដ្ឋានរបស់ក្រសួង ។

១០ : មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវធ្វើការសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ត្រួតពិនិត្យទៅលើអាជីវកម្មដែលប្រព្រឹត្ត ផ្ទុយនឹងគោលការណ៍ របស់ក្រសួងទេសចរណ៍ និងច្បាប់របស់រដ្ឋ និងរាយការណ៍មកក្រសួងទេសចរណ៍ ។

១១ : មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវអនុវត្តអោយបានម៉ឺងម៉ាត់ តាមគោលការណ៍កំណត់របស់ក្រសួងទេសចរណ៍ ។

ទទួលបាននូវសារាចរណែនាំនេះ មន្ទីរទេសចរណ៍ខេត្ត-ក្រុងត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីធ្វើការផ្សព្វផ្សាយណែនាំដល់ម្ចាស់អាជីវកម្ម ទទួលអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ក្នុងការរួមចំណែកបំរើវិស័យទេសចរណ៍ កម្ពុជាអោយអភិវឌ្ឍន៍បានកាន់តែល្អប្រពៃ ។

រដ្ឋមន្ត្រី

ថោង ខុន

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរទេសចរណ៍ខេត្ត-ក្រុង "ដើម្បីមុខការ"
- គ្រប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ